រានមានជីវិតចូលរួមឱ្យពេញលេញក្នុងដំណើរការតុលាការ និងពិចារណាថា តើព័ត៌មានដែលតុលាការប្រមូលបានអាចប្រើប្រាស់បានបន្ទាប់ពី អ.វ.ត.ក ត្រូវបានបិទ។

- **អ្នកផ្តល់ជំនួយ:** ផ្តល់មូនិធិដល់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឧបត្ថម្ភដល់ជនជាតិភាគតិចនៅរស់រានមានជីវិត ដែលរងគ្រោះពីអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ផ្តល់មូលនិធិក្នុងការស៊ើបអង្កេតលើអំពើហិង្សាផ្លូវភេទ និងជម្រុញរដ្ឋាភិបាលឱ្យដោះស្រាយបញ្ហាអំពើហិង្សាផ្លូវភេទដែលកើតមានកន្លងមក។
- **អង្គការសង្គមស៊ីវិល:** ផ្តល់សេវាផ្លូវច្បាប់ វេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្តដល់ជនជាតិភាគតិចនៅរស់រានមានជីវិត បង្កើតក្រុមគាំទ្រ និងសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តច្បាប់ ដើម្បីធានាការពារអ្នកនៅរស់រានមានជីវិត ដែលបានលាតត្រដាងរឿងរ៉ាវរបស់ខ្លួន។
- **សាស្ត្រាចារ្យ និងស្ថាប័នអប់រំ:** ផ្តល់ព័ត៌មានដល់សិស្សអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម និងផ្តល់កម្មវិធីសិក្សាអំពីការការពារអំពើហិង្សាផ្លូវភេទ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។
- **អ្នកស្រាវជ្រាវ និងអ្នកប្រវត្តិសាស្ត្រ:** ស៊ើបអង្កេតអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិច ជាពិសេសផលប៉ះពាល់នៃការរៀបការដោយបង្ខំលើអត្ត-សញ្ញាណវប្បធម៌របស់ពួកគេ។
- **ប្រព័ន្ធផ្សព្វផ្សាយ:** រាយការណ៍អំពីលទ្ធផលរកឃើញនៃការសិក្សាស្រាវជ្រាវទាំងនេះ និងសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីធានាឱ្យមានការរាយការណ៍ត្រឹមត្រូវ និងងាយយល់។
- **សមាជិកសហគមន៍:** អប់រំខ្លួនឯងអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហមពិភាក្សាអំពីបញ្ហានេះជាមួយប្រជាជនដទៃទៀត ជួយអ្នកនៅរស់រានមានជីវិតឱ្យទទួលបានសេវានានា និងទាមទារឱ្យមានការទទួលខុសត្រូវពីជនល្មើស។

*ការសង្ខេបនេះចម្លងចេញពីរបាយការណ៍ទាំងមូល ហើយដែលអាចរកបានពី http://gbvkr.org/*



*ការអនុវត្តន៍ការសម្ភាសន៍សាកល្បង*



*ស្តូបនៅបឹងជើងឯក*

© ២០១៤

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
ផ្ទះលេខ ១ LE0, ផ្លូវលេខ ៤៥០ សង្កាត់ទួលទំពូង២ ភ្នំពេញ កម្ពុជា
http://gbvkr.org/



ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT

# អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច ក្នុងរបបខ្មែរក្រហម

Rochelle Braaf
ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

## ការសិក្សា

ក្នុងឆ្នាំ២០១៣ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាលផ្តោតលើការផ្តល់ជំនួយផ្នែកច្បាប់ បានអនុវត្តការសិក្សាមួយដើម្បីស៊ើបអង្កេតរឿងរ៉ាវរបស់ក្រុមជនជាតិភាគតិច ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានអនុវត្តដោយផ្តោតជាពិសេសលើអំពើហិង្សាផ្លូវភេទលើក្រុមជនជាតិភាគតិចទាំងនេះ។ ដើម្បីប្រមូលព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ យើងបានធ្វើបទសម្ភាសន៍ជាមួយបុរស និងស្ត្រីជាជនវៀតណាម ខ្មែរក្រោម ខ្មែរអ៊ីស្លាម និងចាម និងអ្នកមានប្រវត្តិផ្សេងៗ ទៀតចំនួន១០៥នាក់ ដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ។ បទសម្ភាសន៍ត្រូវបានធ្វើឡើងក្នុងខេត្តចំនួនប្រាំមួយ ហើយអ្នកផ្តល់បទសម្ភាសន៍ត្រូវ បានសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ លើក្រុមជនជាតិភាគតិចទាំងបួនក្រុមនេះ និងផលប៉ះពាល់បច្ចុប្បន្ននៃអំពើហិង្សានេះ លើអ្នកនៅរស់រានមានជីវិត។



*ផ្សារជនជាតិចាម*

## លទ្ធផលរកឃើញទូទៅ

ការសិក្សារបស់យើងរកឃើញថា ដូចគ្នានឹងប្រជាជនទូទៅ ក្រុមជនជាតិភាគតិចក៏ទទួលរងនូវអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមដែរ។ អំពើហិង្សានេះរួមមាន ការបង្ខំ

ឱ្យរៀបការ ការបង្ខំឱ្យរួមភេទ ការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីទទួលបានម្ហូបអាហារ ឬ សិទ្ធិពិសេសផ្សេងៗទៀត (ការរួមភេទដើម្បីរស់រានមានជីវិត) ទាសករផ្លូវភេទ ការយាយីផ្លូវភេទ និងការរំលោភបំពានដទៃទៀត។ ជនរងគ្រោះមួយចំនួនទទួលរងអំពើហិង្សាផ្លូវភេទលើសពីម្តង ហើយក្នុងករណីជាជនរងគ្រោះ និង/ឬជនល្មើសរំលោភសេពសន្ថវៈមានច្រើននាក់ ហើយភាគច្រើននៃជនរងគ្រោះត្រូវបានសម្លាប់បន្ទាប់ពីរំលោភរួច និងពេលខ្លះសាកសពពួកគេត្រូវបានកាត់ផ្តាច់ចេញពីគ្នា។ ជនរងគ្រោះដែលជាជនជាតិភាគតិចស្ទើរតែទាំងអស់ជាស្ត្រី ហើយភាគច្រើនជាស្ត្រីវ័យក្មេង។

នៅក្នុងករណីអំពើហិង្សាផ្លូវភេទភាគច្រើន បទល្មើសត្រូវបានប្រព្រឹត្តិឡើងដោយបុរសដែលមានអាយុចន្លោះពី១៨ ទៅ ៣០ឆ្នាំ ឬចាស់ជាងនេះ ហើយបុរសទាំងនេះភាគច្រើន ជាអ្នកបម្រើការងារឱ្យពួកខ្មែរក្រហម។ មានតែអាជ្ញាធរ ខ្មែរក្រហមប៉ុណ្ណោះដែលជាអ្នករៀបចំការរៀបការដោយបង្ខំ និងបង្ខំឱ្យរួមភេទជាមួយគ្នាបន្ទាប់ពីរៀបការ។ នៅក្នុងករណីបង្ខំឱ្យរៀបការនេះផងដែរ ភាគីប្តីមួយចំនួនបានបង្ខំប្រពន្ធថ្មីឱ្យរួមភេទជាមួយខ្លួន។

ពេលខ្លះ ជនល្មើសធ្វើការរំលោភសេពសន្ថវៈជាក្រុម ដែលអំពើហិង្សាផ្លូវភេទបែបនេះ មានការឯកភាពពីក្រុមជនល្មើសដោយពួកគេដឹងថា មិនមានការដាក់ទណ្ឌកម្មលើខ្លួនឡើយ។ ភស្តុតាងផ្សេងទៀតបង្ហាញថា ជាញឹកញាប់ជនល្មើសប្រព្រឹត្តបទល្មើសដោយបើកចំហ ឧទាហរណ៍ ការបង្ហាញអវយវៈភេទរបស់ជនរងគ្រោះជាសាធារណៈ ការទុកសាកសពជនរងគ្រោះចោលទាំងអាក្រាតនៅទីវាល ឬការជជែកគ្នាពីបទល្មើសផ្លូវភេទ ដែលខ្លួនបានប្រព្រឹត្តដោយបើកចំហ។

មានការរកឃើញពីភាពខុសគ្នាសំខាន់ៗមួយចំនួនរវាងបទពិសោធន៍នៃជនជាតិភាគតិច និងប្រជាជនទូទៅបានជួបប្រទះ។ ទី១ ពួកខ្មែរក្រហមបានបង្ខំជនជាតិភាគតិចមួយចំនួនឱ្យរៀបការជាមួយប្រជាជនខ្មែរ ដើម្បីបំបែកសហគមន៍ទាំងនេះ។ ទី២ ពេលខ្លះស្ត្រី និងកុមារីជនជាតិភាគតិចគឺជាគោលដៅនៃអំពើហិង្សាផ្លូវភេទ ឧទាហរណ៍ ដូចការរំលោភសេពសន្ថវៈ។ ទី៣ ក្នុងករណីដែលជនជាតិភាគតិចជាគោលដៅនៃការសម្លាប់ ឬការកម្ចាត់ដោយរង្គាល


តំបន់សិក្សា

ជាញឹកញាប់ ស្ត្រីត្រូវបានគេរំលោភមុនពេលសម្លាប់។ ទី៤ មានភស្តុតាងបង្ហាញថា ពួកខ្មែរក្រហមលប់បំបាត់សាសនា ការអនុវត្តវប្បធម៌ និងការបង្ខំឱ្យផ្លាស់ទីលំនៅ ការដាក់គុក ការដាក់ទណ្ឌកម្ម និងការសម្លាប់ដោយរង្គាលមកលើជនជាតិភាគតិច។ អំពើហិង្សាផ្លូវភេទក្នុងបរិបទនេះ គឺជាវិធីសាស្ត្រមួយផ្សេងទៀតក្នុងការដាក់ទណ្ឌកម្ម ទារុណកម្ម ការធ្វើឱ្យភ័យតក់ស្លុត និងការបំបែកបំបាក់ក្រុមជនជាតិភាគតិចទាំងនេះ។

## លទ្ធផលរកឃើញជាក់លាក់

ភាគច្រើននៃអ្នកផ្តល់បទសម្ភាសន៍បានឆ្លើយថា ខ្លួនត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរៀបការ។ មួយភាគបីបានឯកភាពថា ការបង្ខំចិត្តរៀបការនេះគឺដោយសារភ័យខ្លាចពីការសម្លាប់ និងដាក់ទណ្ឌកម្ម។ ជនរងគ្រោះភាគច្រើនដែលបដិសេធមិនព្រមរៀបការត្រូវបានគំរាមកំហែង ឬធ្វើទារុណកម្មតាមវិធីមួយចំនួន ហើយជាចុងក្រោយ ពួកគេស្ទើរតែទាំងអស់ត្រូវរៀបការជាមួយដៃគូដែលជ្រើសរើស


ការព្យាបាលតាមបែបព្រះពុទ្ធសាសនាសម្រាប់ជនរងគ្រោះអំពើហិង្សាលើផ្លូវភេទ

ដោយពួកខ្មែរក្រហម។ ជាធម្មតា ជនរងគ្រោះដែលត្រូវបានបង្ខំឱ្យរៀបការក៏ត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរួមភេទដើម្បីបង្កើតកូនសម្រាប់របបរបស់ខ្លួន។ ប្តីប្រពន្ធស្ទើរតែទាំងអស់ ត្រូវបានពួកខ្មែរក្រហមឃ្លាំមើលក្នុងពេលយប់បន្ទាប់ពីពិធីរៀបការ។

ពួកខ្មែរក្រហមបានគ្រប់គ្រងការបែងចែកអាហារ ហើយមនុស្សជាច្រើនខ្វះអាហាររូបត្ថម្ភ និងមានភាពអត់ឃ្លាន ដោយសារមិនមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ។ ដើម្បីរស់ មនុស្សមួយចំនួនបានផ្តល់ការរួមភេទ ដើម្បីបានអាហារ ឬធ្វើការងារងាយស្រួលជាងនេះ។ ការដោះដូរបែបនេះមានគ្រោះថ្នាក់សម្រាប់ជនរងគ្រោះ (និងជនល្មើស) ប្រសិនបើត្រូវគេដឹង និងអាចត្រូវគេសម្លាប់។

អ្នកផ្តល់បទសម្ភាសន៍មួយចំនួន បានស្គាល់ស្ត្រីជនជាតិភាគតិចដែលត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរួមភេទជាទៀងទាត់ ដែលក្នុងករណីភាគច្រើនត្រូវបានបង្ខំឱ្យរួមភេទពីក្រុមបុរស។ ក្នុងករណីមួយចំនួនទៀត ស្ត្រីទាំងនោះចុងក្រោយត្រូវបានគេសម្លាប់។

អ្នកផ្តល់សម្ភាសន៍ជាច្រើនបានឆ្លងកាត់ បានឃើញ និងបានឮអំពីការយាយីផ្លូវភេទ (មុន ឬ ក្រោយពេលស្លាប់) ការចំអកម៉ាក់ងាយផ្លូវភេទ និងការលូកស្ទាប។ មនុស្សមួយចំនួនបានឃើញការបង្ហាញអវយវៈភេទរបស់ជនរងគ្រោះជាសាធារណៈ ហើយមនុស្សមួយចំនួនទៀតបានពណ៌នាអំពីសកម្មភាពដែលអ្នកបំពានផ្លូវភេទ ស៊ីសាច់ជនរងគ្រោះជាអាហារ។

ខណៈពេលដែលជនជាតិភាគតិចមួយចំនួនដែលនៅរស់រានមានជីវិត បានបន្តទទួលរងការឈឺចាប់ពីរបួសផ្នែករាងកាយដោយសារអំពើហិង្សាផ្លូវភេទ ក៏នៅមានជនជាតិភាគតិចដែលនៅរស់រានមានជីវិត ជាច្រើនទៀតបានបង្ហាញពីបញ្ហាសុខភាពផ្លូវចិត្ត រួមទាំង កំហឹង ទុក្ខសោក ភាពភ័យខ្លាច សុបិន្តអាក្រក់ ការធ្លាក់ទឹកចិត្ត និងមានគំនិតចង់សម្លាប់ខ្លួន។ អ្នកនៅរស់រានមានជីវិតមួយចំនួនប៉ុណ្ណោះបានទទួលការព្យាបាលតាមវេជ្ជសាស្ត្រ និងមួយចំនួនទៀតបានទាក់ទងសុំសេវាផ្លូវច្បាប់ និងសេវាសុខភាពផ្លូវចិត្ត ប៉ុន្តែភាគច្រើននៃជនរងគ្រោះដទៃទៀត មិនបានដឹងអំពីសេវាទាំងនេះឡើយ។ ប្តីប្រពន្ធ ឬសាច់ញាតិរបស់អ្នកនៅរស់រានមានជីវិត បានជួយពួកគេក្នុងការប្រឈមមុខអ្វីដែលបានកើតឡើងចំពោះពួកគេក្នុងពេលអតីតកាល។ ជនរងគ្រោះដទៃទៀតបាននិយាយថា សាសនា និងមេសាសនា ឬ សេវាសុខភាពផ្លូវចិត្ត បានជួយពួកគេឲ្យមានការធូរស្រាលខ្លះៗ ហើយជួយដោះស្រាយកំហឹង ការអស់សង្ឃឹម និងទុក្ខសោករបស់ខ្លួន។

នៅពេលសាកសួរថាតើអ្វីដែលអាចជួយពួកគេបានក្នុងពេលបច្ចុប្បន្ននេះ អ្នកនៅរស់រានមានជីវិតឆ្លើយថា ពួកគេចង់ឱ្យមានការកាត់ទោស និងចេញសាលក្រមលើពួកមេដឹកនាំខ្មែរក្រហមឱ្យបានឆាប់រហ័ស ដើម្បីជាការរំឭកដល់អ្នកដែលបានស្លាប់ក្នុងរបបនេះ ជាកំណត់ត្រានៃអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ជាពិសេស សម្រាប់យុវជន។ ក្រៅពីនេះពួកគេចង់បានសេវាសុខភាពផ្លូវចិត្ត និងសេវាផ្សេងៗទៀត។

## អនុសាសន៍

របាយការណ៍ផ្តល់ជាអនុសាសន៍ថា ៖

- **រាជរដ្ឋាភិបាលកម្ពុជា:** ទទួលស្គាល់ និងផ្តន្ទាទោសចំពោះអំពើហិង្សាក្នុងរបបខ្មែរក្រហម គាំទ្រឱ្យមានការស៊ើបអង្កេតអំពើហិង្សានេះ សាងសង់ស្តូបរំឭកវិញ្ញាណក្ខ័ន្ធ និងផ្តល់សំណងដល់អ្នកនៅរស់រានមានជីវិត។
- **អ.វ.ត.ក:** បញ្ចូលបទល្មើសហិង្សាផ្លូវភេទទ្រង់ទ្រាយធំលើជនជាតិភាគតិចទៅក្នុងសំណុំរឿង០០៣ និង ០០៤ គាំទ្រជនជាតិភាគតិចវៀតណាម នៅរស់